ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខៈ ៦១ អយក.សណន

# សេចក្តីណែនាំស្តីពី
# ការរៀបចំផែនការសាលារៀន
# សម្រាប់សាលារៀនមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សាចំណេះទូទៅ

## ១. សេចក្តីផ្តើម

ក្រសួងអប់រំ យុវជន និងកីឡា គ្រោងនឹងបញ្ចប់ការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ ស្របតាមក្របខណ្ឌពេលវេលាដែលបានកំណត់។ ទន្ទឹមនឹងនេះ ក្រសួងនឹងរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០២៤-២០២៨ ឱ្យមានលក្ខណៈកាន់តែស៊ីជម្រៅ និងគ្រប់ជ្រុងជ្រោយ ស្របតាមការធ្វើបរិវត្តកម្មក្នុងវិស័យអប់រំដើម្បីឆ្លើយតប និងមានសង្គតិភាពជាមួយនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០២៤-២០២៨ របស់រាជរដ្ឋាភិបាលកម្ពុជា គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពស្តីពីការអប់រំនៅកម្ពុជាឆ្នាំ២០៣០ គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម ២០១៥-២០២៥ និងក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច-សង្គមឌីជីថល ២០២១-២០២៥ ។

នៅក្នុងអាណត្តិរាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៧ នៃរដ្ឋសភា ក្រសួងអប់រំ យុវជន និងកីឡា បានកំណត់នូវកំណែទម្រង់សាលារៀនជាអាទិភាព តាមរយៈការអនុវត្ត "ស្តង់ដាសាលារៀនគំរូ" និង "ពានរង្វាន់សាលាគំរូ សម្តេចមហាបវរធិបតី" និងការចូលរួមអនុវត្ត "យុទ្ធនាការសាលារៀនស្អាតគ្មានសំរាម" ដើម្បីលើកកម្ពស់គុណភាពអប់រំ។ ក្រសួងបានដាក់ឱ្យអនុវត្តស្តង់ដាសាលារៀនគំរូចំនួន ៥ សម្រាប់មត្តេយ្យសិក្សារហូតដល់មធ្យមសិក្សា ដោយបានកំណត់វិធានការ និងសូចនាករពាក់ព័ន្ធនឹង ១).ការលើកកម្ពស់អភិបាលកិច្ចសាលារៀន, ២).ការពិនិត្យកែសម្រួល និងរៀបចំកម្មវិធីសិក្សា និងសកម្មភាពក្រៅម៉ោងសិក្សាឱ្យស្របទៅតាមតម្រូវការក្នុងការពង្រឹងចំណេះដឹង វិន័យ សីលធម៌ និងឥរិយាបថរបស់សិស្ស, ៣).ការយកចិត្តទុកដាក់លើសុខភាពរបស់សិស្ស តាមរយៈកម្មវិធីអាហារូបត្ថម្ភដល់កុមារនិងការត្រួតពិនិត្យគុណភាពចំណីអាហារនៅតាមសាលារៀន, និង ៤).ការជំរុញនិងលើកទឹកចិត្តការចូលរួមរបស់មាតាបិតា អ្នកអាណាព្យាបាល និងសហគមន៍ ក្នុងការអប់រំស្របតាមពាក្យស្លោកភាពជាដៃគូ រដ្ឋ និងសហគមន៍ដើម្បីការអប់រំ។

សាលារៀនគំរូ គឺជាសាលារៀនដែលសម្រេចបាននូវស្តង់ដាទាំង ៥ រួមមាន៖ ស្តង់ដាទី១-លទ្ធផលសិក្សារបស់សិស្ស, ស្តង់ដាទី២-ការបង្រៀននិងរៀន, ស្តង់ដាទី៣-ការចូលរួមរបស់សហគមន៍, ស្តង់ដាទី៤-ដំណើរប្រតិបត្តិការនិងរដ្ឋបាលសាលារៀន, និងស្តង់ដាទី៥-គណនេយ្យភាពរបស់សាលារៀន។

ដើម្បីសម្រេចបានស្តង់ដាសាលារៀនគំរូ នាយកសាលា ឬគណៈកម្មការគ្រប់គ្រងសាលារៀន ត្រូវមានបំណិនក្នុងការកៀរគរធនធានពីគ្រប់មជ្ឈដ្ឋាន បង្កើនការចូលរួម និងជំនឿទុកចិត្តពីគ្រប់អ្នកពាក់ព័ន្ធ ក្នុងការអនុវត្តសកម្មភាពនៅកម្រិតសាលារៀន ជាពិសេសសាលារៀនត្រូវធ្វើស្វ័យវាយតម្លៃសាលារៀន ដើម្បីពិនិត្យមើលអំពីវឌ្ឍនភាព និងបញ្ហា

ប្រឈមនានាក្នុងការអនុវត្តសកម្មភាព ដែលជាមូលដ្ឋានសម្រាប់ធ្វើការកែលម្អចំណុចខ្វះខាតតាមរយៈការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន និងផែនការប្រតិបត្តិប្រចាំឆ្នាំសាលារៀន ឬផែនការកែលម្អសាលារៀន ព្រមទាំងការពិនិត្យតាមដាន និងវាយតម្លៃសាលារៀនតាមឆ្នាំសិក្សានីមួយៗ។

ក្នុងន័យនេះ គ្រឹះស្ថានសិក្សាសាធារណៈ ត្រូវរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន២០២៤-២០២៨ ផែនការយុទ្ធសាស្ត្រថវិកា ២០២៤-២០២៦ និងផែនការប្រតិបត្តិប្រចាំឆ្នាំ២០២៤ និងឆ្នាំបន្តបន្ទាប់ ដោយឆ្លើយតបនឹងតម្រូវការជាក់ស្តែងក្នុងមូលដ្ឋាន ស្របតាមទិសដៅថ្នាក់ ក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត និងថ្នាក់ជាតិ ក្នុងការផ្តល់សេវាអប់រំ និងជួយឱ្យកុមារគ្រប់រូបមានលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយគុណភាព សមធម៌ និងបរិយាបន្ន។

## ២. វត្ថុបំណង

**វត្ថុបំណងនៃសេចក្តីណែនាំរួមមាន៖**

- ផ្តល់ការណែនាំផ្នែកបច្ចេកទេសក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន ផែនការយុទ្ធសាស្ត្រថវិកាសាលារៀន និងការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន ឬផែនការកែលម្អសាលារៀន ឆ្លើយតបទៅនឹងការសម្រេចអាទិភាពនៃកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា
- ផ្តល់ក្របខណ្ឌសម្រាប់ការពិនិត្យជាប្រចាំឆ្នាំ រួមគ្នារវាងសាលារៀន និងភាគីពាក់ព័ន្ធ។

## ៣. យន្តការនៃការរៀបចំផែនការសាលារៀន

ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន ផែនការយុទ្ធសាស្ត្រថវិកាសាលារៀន និងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន ឬផែនការកែលម្អសាលារៀន ត្រូវដឹកនាំដោយនាយកសាលារៀន និងគណៈកម្មការគ្រប់គ្រងសាលារៀន ដោយមានការចូលរួមពីសមាជិកគណៈកម្មការគ្រប់គ្រងសាលារៀន គ្រូបង្រៀន អាជ្ញាធរដែនដី ក្រុមប្រឹក្សាឃុំសង្កាត់ មេឃុំ/ចៅសង្កាត់ ប្រធានភូមិ ប្រធានក្រុម ក្រុមប្រឹក្សាយុវជន និងកុមារ តំណាងសិស្សានុសិស្ស មាតាបិតាសិស្ស អ្នកអាណាព្យាបាល អង្គការដៃគូអភិវឌ្ឍ និងស្ថាប័នពាក់ព័ន្ធផ្សេងៗក្នុងសហគមន៍ ដើម្បីពិភាក្សារួមគ្នាលើតម្រូវការចាំបាច់របស់សាលារៀន និងសហគមន៍លើបញ្ហាប្រឈមចម្បងៗ និងលទ្ធផលសិក្សារបស់សិស្សឱ្យមានគុណភាព និងប្រសិទ្ធភាពខ្ពស់ ជាពិសេសកុមារបានចូលរៀនគ្រប់រូប សិស្សរៀនចេះ ប្រឡងជាប់ និងបន្តរៀនចប់តាមកម្រិតសិក្សានីមួយៗ។

នាយកសាលា និងគណៈកម្មការគ្រប់គ្រងសាលារៀន ត្រូវសម្របសម្រួល និងដឹកនាំការរៀបចំផែនការសាលារៀនតាមយន្តការដូចខាងក្រោម៖

១. គ្រប់គ្រងទិន្នន័យ ស្ថិតិ សូចនាករអប់រំ សុខភាព សង្គម និងសេដ្ឋកិច្ច ក្នុងភូមិសាស្ត្រ ភូមិ ឃុំ សង្កាត់ ដើម្បីជាមូលដ្ឋានក្នុងការរៀបចំផែនទីខ្នងផ្ទះ ផែនទីសិក្សាសាលារៀន និងព័ត៌មានស្ថានភាពគ្រួសារនីមួយៗ នៅតាមភូមិ ឃុំ សង្កាត់។

២. រៀបចំឱ្យមានការសហការគ្នា និងធ្វើការរួមគ្នាក្នុងការរៀបចំផែនការសាលារៀន (ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន ផែនការយុទ្ធសាស្ត្រថវិកាសាលារៀន និងផែនការប្រតិបត្តិប្រចាំឆ្នាំសាលារៀន ឬផែនការកែលម្អសាលារៀន) និងផែនការវិនិយោគឃុំ សង្កាត់។

៣. រៀបចំឱ្យមានការពិនិត្យតាមដាន និងវាយតម្លៃប្រចាំឆមាស ឬប្រចាំឆ្នាំសម្រាប់ផែនការប្រតិបត្តិប្រចាំឆ្នាំ និងពាក់កណ្តាលអាណត្តិ និងចុងអាណត្តិ សម្រាប់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន រួមគ្នា លើស្តង់ដាសាលារៀនគំរូ រួមមាន លទ្ធផលសិក្សារបស់សិស្ស ការបង្រៀននិងរៀន ការចូលរួមរបស់សហគមន៍ ដំណើរប្រតិបត្តិការនិងរដ្ឋបាលសាលារៀន និងគណនេយ្យភាព។

## ៤. ក្របខណ្ឌពេលវេលា និងទម្រង់ផែនការសាលារៀន

### ៤.១. ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន

### ៤.១.១ ក្របខណ្ឌពេលវេលានៃការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន

- ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀននឹងប្រព្រឹត្តទៅប្រាំឆ្នាំម្តង ត្រូវឆ្លើយតបនឹងស្តង់ដាសាលារៀនគំរូ ព្រមទាំងស្របនឹងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ដែលមានសមាសភាពចូលរួមមកពី គណៈកម្មការគ្រប់គ្រងសាលារៀន គណៈគ្រប់គ្រងសាលា គ្រូបង្រៀន អាជ្ញាធរដែនដី ក្រុមប្រឹក្សាឃុំសង្កាត់ ប្រធានភូមិ ក្រុមប្រឹក្សាយុវជននិងកុមារ តំណាងសិស្សានុសិស្ស មាតាបិតាសិស្ស អ្នកអាណាព្យាបាល អង្គការដៃគូអភិវឌ្ឍ ស្ថាប័នពាក់ព័ន្ធផ្សេងៗក្នុងសហគមន៍ និងអ្នកពាក់ព័ន្ធផ្សេងទៀត

- នៅរៀងរាល់ ៥ឆ្នាំ ម្តង សាលារៀនទាំងអស់ត្រូវរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន ក្រោមការសម្របសម្រួលពីគណៈកម្មការគ្រប់គ្រងសាលារៀន និងនាយកសាលាដើម្បីដឹកនាំកិច្ចប្រជុំ ពិភាក្សាលើបញ្ហាដែលកើតឡើងក្នុងសាលារៀន និងសហគមន៍ទាំងមូល ដោយផ្អែកលើលទ្ធផលស្វ័យវាយតម្លៃសាលារៀនគំរូ

- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន រយៈពេល ៥ឆ្នាំនេះ នឹងត្រូវគណៈកម្មការគ្រប់គ្រងសាលារៀន យកទៅដាក់ជាធាតុចូលនៅក្នុងផែនការវិនិយោគរបស់ឃុំ សង្កាត់ ដើម្បីកៀរគរថវិកាពីដៃគូអភិវឌ្ឍ និងស្ថាប័នពាក់ព័ន្ធផ្សេងៗ។

ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន ២០២៤-២០២៨ ត្រូវអនុវត្តទៅតាមកាលបរិច្ឆេទកំណត់ដូចខាងក្រោម ៖

| កាលបរិច្ឆេទ | សកម្មភាព |
|---|---|
| សប្តាហ៍ទី៣<br>ខែតុលា ឆ្នាំ២០២៣ | ណែនាំអំពីការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន២០២៤-២០២៨ ដល់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត |
| សប្តាហ៍ទី៤<br>ខែតុលា ឆ្នាំ២០២៣ | មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ណែនាំអំពីការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន២០២៤-២០២៨ ដល់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាល ក្រុង ស្រុក ខណ្ឌ |
| | ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាល ក្រុង ស្រុក ខណ្ឌ ណែនាំអំពីការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន២០២៤-២០២៨ ដល់សាលារៀន |
| សប្តាហ៍ទី១<br>ខែវិច្ឆិកា ឆ្នាំ២០២៣ | សាលារៀនប្រជុំរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន២០២៤-២០២៨ ជាមួយគ្រប់ភាគីពាក់ព័ន្ធ |
| សប្តាហ៍ទី២<br>ខែវិច្ឆិកា ឆ្នាំ២០២៣ | សេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន២០២៤-២០២៨ និងផ្តល់យោបល់បន្ថែមពីអ្នកពាក់ព័ន្ធ |
| សប្តាហ៍ទី៣<br>ខែវិច្ឆិកា ឆ្នាំ២០២៣ | សេចក្តីព្រាងចុងក្រោយ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន ២០២៤-២០២៨ និងផ្តល់យោបល់បន្ថែមពីអ្នកពាក់ព័ន្ធ |
| សប្តាហ៍ទី៤<br>ខែវិច្ឆិកា ឆ្នាំ២០២៣ | បញ្ចប់ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន ២០២៤-២០២៨ |

### ៤.១.២ ទម្រង់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន (៥ឆ្នាំ)

ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន ត្រូវឆ្លើយតបតាមស្តង់ដាសាលារៀនគំរូ ដែលរួមមាន ៥ ស្តង់ដា គឺ ទី១) លទ្ធផលសិក្សារបស់សិស្ស ទី២) ការបង្រៀននិងរៀន ទី៣) ការចូលរួមរបស់សហគមន៍ ទី៤) ដំណើរ

ប្រតិបត្តិការនិងរដ្ឋបាលសាលារៀន និង ទី៥) គណនេយ្យភាព។ ខ្លឹមសារលម្អិតនៃស្តង់ដាសាលារៀនគំរូមានដូចក្នុងឯកសារជូនភ្ជាប់។ ទម្រង់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន មានដូចខាងក្រោម៖

១. សេចក្តីផ្តើម
២. ប្រវត្តិសាលារៀន
៣. ចក្ខុវិស័យ
៤. បេសកកម្ម
៥. វិភាគស្ថានភាព និងបញ្ហាប្រឈម
៦. សូចនាករ និងចំណុចដៅរបស់សាលារៀន

តារាងទី១៖ សូចនាករ និងចំណុចដៅតាមឆ្នាំនីមួយៗ សម្រាប់រយៈពេល ៥ឆ្នាំ (២០២៤-២០២៨)

| ល.រ | សូចនាករ | ឆ្នាំមូលដ្ឋាន ២០២៣ | ចំណុចដៅ | | | | |
|---|---|---|---|---|---|---|---|
| | | | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ |
| ស្តង់ដាទី១៖ លទ្ធផលសិក្សារបស់សិស្ស | | | | | | | |
| | • ..................... | | | | | | |
| ស្តង់ដាទី២៖ ការបង្រៀននិងរៀន | | | | | | | |
| | • ..................... | | | | | | |
| ស្តង់ដាទី៣៖ ការចូលរួមរបស់សហគមន៍ | | | | | | | |
| | • ..................... | | | | | | |
| ស្តង់ដាទី៤៖ ដំណើរប្រតិបត្តិការ និងរដ្ឋបាលសាលារៀន | | | | | | | |
| | • ..................... | | | | | | |
| ស្តង់ដាទី៥៖ គណនេយ្យភាព | | | | | | | |
| | • | | | | | | |

៧. យុទ្ធសាស្ត្រ និងសកម្មភាព

យុទ្ធសាស្ត្រទី១៖ ..........................................................................................

- សកម្មភាព៖ ..........................................................................................
- សកម្មភាព៖ ..........................................................................................

..........................................................................................................

៨. ចំណោលតម្រូវការថវិកា

តារាងទី២៖ ចំណោលតម្រូវការថវិកាដំណើរការសាលារៀនតាមឆ្នាំនីមួយៗ សម្រាប់រយៈពេល ៥ឆ្នាំ

| ល.រ | សកម្មភាព | ឆ្នាំគោល ២០២៣ | ចំណោល | | | | |
|---|---|---|---|---|---|---|---|
| | | | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ |
| ១ | **គាំទ្រដំណើរការសាលារៀន** | | | | | | |
| ១.១ | កិច្ចដំណើរការរដ្ឋបាល | | | | | | |
| ១.២ | ការថែទាំ និងជួសជុលផ្សេងៗ | | | | | | |
| ២ | **កែលម្អគុណភាពបង្រៀន និងរៀន** | | | | | | |
| ២.១ | ការចូលរៀនដោយសមធម៌ និងបង្ការសិស្សបោះបង់ | | | | | | |
| ២.២ | សម្ភារៀន បង្រៀន និងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ | | | | | | |
| ២.៣ | ការកែលម្អបរិស្ថាន និងទីធ្លាកម្សាន្ត | | | | | | |

| ល.រ | សកម្មភាព | ឆ្នាំគោល ២០២៣ | ចំណោល | | | | |
|---|---|---|---|---|---|---|---|
| | | | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ |
| ២.៤ | អប់រំបំណិនជីវិត កីឡា ការងារយុវជន និងកុមារ | | | | | | |
| សរុបរួម | | | | | | | |

៩. យន្តការពិនិត្យតាមដាន និងវាយតម្លៃ

១០. ឧបសម្ព័ន្ធ

## ៤.២ ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាសាលារៀន

### ៤.២.១ ក្របខណ្ឌពេលវេលានៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកាសាលារៀន

- ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាសាលារៀន (៣ឆ្នាំរំកិល) នឹងប្រព្រឹត្តទៅរៀងរាល់ឆ្នាំ និងត្រូវឆ្លើយតបនឹងស្តង់ដាសាលារៀនគំរូ ព្រមទាំងស្របនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន ដែលមានសមាសភាពចូលរួមមកពី គណៈកម្មការគ្រប់គ្រងសាលារៀន គណៈគ្រប់គ្រងសាលា គ្រូបង្រៀន អាជ្ញាធរដែនដី ក្រុមប្រឹក្សាឃុំសង្កាត់ ប្រធានភូមិ ក្រុមប្រឹក្សាយុវជននិងកុមារ តំណាងសិស្សានុសិស្ស មាតាបិតាសិស្ស អ្នកអាណាព្យាបាល អង្គការដៃគូអភិវឌ្ឍ ស្ថាប័នពាក់ព័ន្ធផ្សេងៗក្នុងសហគមន៍ និងអ្នកពាក់ព័ន្ធផ្សេងទៀត
- ក្របខណ្ឌពេលវេលានៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកាសាលារៀន ត្រូវស្របតាមគោលការណ៍ណែនាំស្តីពីមូលនិធិដំណើរការសាលារៀនសាធារណៈ (SOF)។

### ៤.២.២ ទម្រង់ផែនការយុទ្ធសាស្ត្រថវិកាសាលារៀន

ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាសាលារៀន ត្រូវឆ្លើយតបតាមស្តង់ដាសាលារៀនគំរូ ដែលរួមមាន ៥ស្តង់ដា គឺ ទី១) លទ្ធផលសិក្សារបស់សិស្ស ទី២) ការបង្រៀននិងរៀន ទី៣) ការចូលរួមរបស់សហគមន៍ ទី៤) ដំណើរប្រតិបត្តិការនិងរដ្ឋបាលសាលារៀន និង ទី៥) គណនេយ្យភាព។ ខ្លឹមសារលម្អិតនៃស្តង់ដាសាលារៀនគំរូមានដូចក្នុងឯកសារជូនភ្ជាប់។ ទម្រង់ផែនការយុទ្ធសាស្ត្រថវិកាសាលារៀន មានដូចខាងក្រោម៖

១. សេចក្តីផ្តើម

២. ចក្ខុវិស័យ

៣. បេសកកម្ម

៤. វឌ្ឍនភាពនៃសូចនាករគន្លឹះ និងបញ្ហាប្រឈម

៥. សូចនាករសមិទ្ធកម្ម និងគោលដៅ

តារាងទី១៖ សូចនាករសមិទ្ធកម្ម និងគោលដៅ

| ស្តង់ដា និងសូចនាករ | ឆ្នាំគ្រោងថវិកា ២០២៤ (លានរៀល) | គោលដៅសូចនាករសមិទ្ធកម្ម | | | | | |
|---|---|---|---|---|---|---|---|
| | | ឆ្នាំមុន* (២០២២) | ឆ្នាំបច្ចុប្បន្ន (២០២៣) | ឆ្នាំគ្រោងថវិកា (២០២៤) | | ឆ្នាំគ្រោងថវិកា (២០២៥) | ឆ្នាំគ្រោងថវិកា (២០២៦) |
| | | | | គោលដៅ | មូលហេតុនៃការផ្លាស់ប្តូរ (ធៀបនឹងគោលដៅឆ្នាំ២០២៣) | | |
| សូចនាករលទ្ធផលចុងក្រោយ | | | | | | | |
| ស្តង់ដាទី១៖ លទ្ធផលសិក្សារបស់សិស្ស | | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ | | | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ............................... | | | | | | | |
| ស្តង់ដាទី២៖ ការបង្រៀននិងរៀន | | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ | | | | | | | |
| ............................... | | | | | | | |
| ស្តង់ដាទី៣៖ ការចូលរួមរបស់សហគមន៍ | | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ | | | | | | | |
| ............................... | | | | | | | |
| ស្តង់ដាទី៤៖ ដំណើរប្រតិបត្តិការ និងរដ្ឋបាលសាលារៀន | | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ | | | | | | | |
| ............................... | | | | | | | |
| ស្តង់ដាទី៥៖ គណនេយ្យភាព | | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ | | | | | | | |
| ............................... | | | | | | | |

## ៦. តម្រូវការថវិកា

តារាងទី២៖ ការកំណត់តម្រូវការចំណាយ

| ល.រ | សកម្មភាព | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ N | | | | គ្រោងតម្រូវការវិនិយោគ សម្រាប់ឆ្នាំ N+1 | | | | គ្រោងតម្រូវការវិនិយោគ សម្រាប់ឆ្នាំ N+2 | | | | គ្រោងតម្រូវការវិនិយោគ សម្រាប់ឆ្នាំ N+3 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ថវិការដ្ឋ | ថវិកាដៃគូ | ថវិកាសហគមន៍ | ថវិកាផ្សេងៗ | ថវិការដ្ឋ | ថវិកាដៃគូ | ថវិកាសហគមន៍ | ថវិកាផ្សេងៗ | ថវិការដ្ឋ | ថវិកាដៃគូ | ថវិកាសហគមន៍ | ថវិកាផ្សេងៗ | ថវិការដ្ឋ | ថវិកាដៃគូ | ថវិកាសហគមន៍ | ថវិកាផ្សេងៗ |
| ១ | គាំទ្រដំណើរការសាលារៀន | | | | | | | | | | | | | | | | |
| ១.១ | កិច្ចដំណើរការរដ្ឋបាល | | | | | | | | | | | | | | | | |
| ១.២ | ការថែទាំ និងជួសជុលផ្សេងៗ | | | | | | | | | | | | | | | | |
| ២ | កែលម្អគុណភាពបង្រៀន និងរៀន | | | | | | | | | | | | | | | | |
| ២.១ | ការចូលរៀនដោយសមធម៌ និងបង្ការសិស្សបោះបង់ | | | | | | | | | | | | | | | | |
| ២.២ | សម្ភាររៀន បង្រៀន និងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ | | | | | | | | | | | | | | | | |
| ២.៣ | ការកែលម្អបរិស្ថាន និងទីធ្លាកម្សាន្ត | | | | | | | | | | | | | | | | |
| ២.៤ | អប់រំបំណិនជីវិត កីឡា ការងារយុវជន និងកុមារ | | | | | | | | | | | | | | | | |
| សរុបរួម | | | | | | | | | | | | | | | | | |

## ៤.៣ ការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន

### ៤.៣.១ ក្របខណ្ឌពេលវេលានៃការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន

- ការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀននឹងត្រូវប្រព្រឹត្តទៅប្រចាំឆ្នាំ ដែលមានសមាសភាពចូលរួមមកពីសមាជិកគណៈកម្មាការគ្រប់គ្រងសាលារៀន គណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន អាជ្ញាធរដែនដី ក្រុមប្រឹក្សាឃុំសង្កាត់ ប្រធានភូមិ ក្រុមប្រឹក្សាយុវជននិងកុមារ តំណាងសិស្សានុសិស្ស មាតាបិតាសិស្ស អ្នកអាណាព្យាបាល តំណាងសហគមន៍អង្គការដៃគូអភិវឌ្ឍ និងស្ថាប័នពាក់ព័ន្ធផ្សេងៗក្នុងសហគមន៍។

- ផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀននេះ នឹងត្រូវគណៈកម្មការគ្រប់គ្រងសាលារៀន យកទៅដាក់ជាជាតុចូលនៅក្នុងផែនការវិនិយោគរបស់ឃុំ សង្កាត់ ដើម្បីកៀរគរថវិកាពីដៃគូអភិវឌ្ឍ និងស្ថាប័នពាក់ព័ន្ធផ្សេងៗ។

ការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ២០២៤ របស់សាលារៀន ត្រូវអនុវត្តទៅតាមកាលបរិច្ឆេទកំណត់ដូចខាងក្រោម៖

| កាលបរិច្ឆេទ | សកម្មភាព |
|---|---|
| សប្តាហ៍ទី៣<br>ខែតុលា ឆ្នាំ២០២៣ | ណែនាំអំពីការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ២០២៤ របស់សាលារៀន ដល់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត |
| សប្តាហ៍ទី៤<br>ខែតុលា ឆ្នាំ២០២៣ | មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ណែនាំអំពីការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ២០២៤ របស់សាលារៀន ដល់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាល ក្រុង ស្រុក ខណ្ឌ |
| | ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាល ក្រុង ស្រុក ខណ្ឌ ណែនាំអំពីការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ២០២៤ របស់សាលារៀន ដល់គ្រប់សាលារៀន |
| សប្តាហ៍ទី១<br>ខែវិច្ឆិកា ឆ្នាំ២០២៣ | សាលារៀនប្រជុំរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ២០២៤ ជាមួយគ្រប់ភាគីពាក់ព័ន្ធ |
| សប្តាហ៍ទី២<br>ខែវិច្ឆិកា ឆ្នាំ២០២៣ | សេចក្តីព្រាងផែនការប្រតិបត្តិប្រចាំឆ្នាំ២០២៤ និងផ្តល់យោបល់បន្ថែមពីអ្នកពាក់ព័ន្ធ |
| សប្តាហ៍ទី៣<br>ខែវិច្ឆិកា ឆ្នាំ២០២៣ | សេចក្តីព្រាងចុងក្រោយផែនការប្រតិបត្តិប្រចាំឆ្នាំ២០២៤ និងផ្តល់យោបល់បន្ថែមពីអ្នកពាក់ព័ន្ធ |
| សប្តាហ៍ទី៤<br>ខែវិច្ឆិកា ឆ្នាំ២០២៣ | បញ្ចប់ ផែនការប្រតិបត្តិប្រចាំឆ្នាំ២០២៤ របស់សាលារៀន |

### ៤.៣.២ ទម្រង់ផែនការប្រតិបត្តិប្រចាំឆ្នាំសាលារៀន

១. សេចក្តីផ្តើម
២. ស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈម
៣. គោលបំណង
៤. សូចនាករ និងចំណុចដៅរបស់សាលារៀន
៥. សកម្មភាពអនុវត្ត

| លទ្ធផលរំពឹងទុក | សកម្មភាព | ក្របខណ្ឌពេលវេលា | | | | អ្នកទទួលខុសត្រូវ | ប្រភពធនធាន | | | ថវិកាសរុប |
|---|---|---|---|---|---|---|---|---|---|---|
| | | ត្រី១ | ត្រី២ | ត្រី៣ | ត្រី៤ | | រដ្ឋ | សហគមន៍ | ដៃគូ | |
| | | | | | | | 1 | 2 | 3 | 4 = 1 +2 + 3 |
| ស្តង់ដាទី១៖ លទ្ធផលសិក្សារបស់សិស្ស | | | | | | | | | | |
| .................. | .................. | | | | | | | | | |
| ស្តង់ដាទី២៖ ការបង្រៀននិងរៀន | | | | | | | | | | |
| ............ | ............... | | | | | | | | | |
| ស្តង់ដាទី៣៖ ការចូលរួមរបស់សហគមន៍ | | | | | | | | | | |
| ............ | ............... | | | | | | | | | |
| ស្តង់ដាទី៤៖ ដំណើរប្រតិបត្តិការ និងរដ្ឋបាលសាលារៀន | | | | | | | | | | |
| ............ | ............... | | | | | | | | | |
| ស្តង់ដាទី៥៖ គណនេយ្យភាព | | | | | | | | | | |
| ............ | ............... | | | | | | | | | |

## ៥. យន្តការពិនិត្យតាមដាន និងវាយតម្លៃផែនការសាលារៀន

ដើម្បីឱ្យការពិនិត្យតាមដាន និងវាយតម្លៃផែនការសាលារៀនប្រកបដោយសក្តិសិទ្ធិភាព និងប្រសិទ្ធភាពសាលារៀនត្រូវ៖

- បង្កើតក្រុមការងារពិនិត្យតាមដាន និងវាយតម្លៃផែនការសាលារៀន
- ពិនិត្យលើវឌ្ឍនភាពដែលសម្រេចបាន និងទិសដៅបន្តរបស់សាលារៀនដែលបានកំណត់
- កំណត់អំពីមេរៀនពិសោធន៍ ដែលទទួលបានពីការអនុវត្តកន្លងមក
- កំណត់បញ្ហានានា សម្រាប់ជាមូលដ្ឋានក្នុងការរៀបចំផែនការសាលារៀនឆ្នាំបន្ទាប់
- ពិនិត្យតាមដាន និងវាយតម្លៃគ្រប់កម្មវិធី និងសកម្មភាពទាំងអស់
- កំណត់កាលបរិច្ឆេទ និងការផ្សព្វផ្សាយលទ្ធផល នៃការពិនិត្យតាមដាន និងវាយតម្លៃ
- ទទួលមតិយោបល់ពីអ្នកពាក់ព័ន្ធ លើការអនុវត្តផែនការសាលារៀន ដើម្បីកែលម្អផែនការនៅពេលបន្ទាប់។

ទទួលបានសេចក្តីណែនាំនេះ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់គ្រប់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងគ្រឹះស្ថានសិក្សាសាធារណៈ ព្រមទាំងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់។

ថ្ងៃព្រហស្បតិ៍ ៤កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល :**

- គ្រប់រដ្ឋបាលរាជធានី ខេត្ត
- គ្រប់អគ្គនាយកដ្ឋាន និងអគ្គាធិការដ្ឋាន
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"
- កាលប្បវត្តិ
- ឯកសារ នាយកដ្ឋានផែនការ